# សម្ភវជាតក




*ព្រះសាស្តាកាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធបញ្ញាបារមី បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **រជ្ជញ្ច បដិបជ្ជាស្មា** ដូច្នេះជាដើម ។*

*រឿងរ៉ាវបច្ចុប្បន្ននឹងមានជាក់ច្បាស់ក្នុងមហាឧមង្គជាតក (សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក មហានិបាត មហោសថជាតក បិដកលេខ ៦២ ទំព័រ ១០២) ។*

*ក្នុងអតីតកាល មានព្រះរាជាព្រះនាម **ធនញ្ជយកោរព្យ** សោយរាជសម្បត្តិក្នុងនគរឥន្ទបត្ត ក្នុងកុរុរដ្ឋ ។ ព្រាហ្មណ៍បុរោហិតឈ្មោះ **សុចិរតៈ** ជាអ្នកប្រៀនប្រដៅនូវអត្ថនិងធម៌ដល់ព្រះរាជានោះ ។ ព្រះរាជាកាលធ្វើបុណ្យទាំងឡាយមានឲ្យទានជាដើម រមែងគ្រប់គ្រង*

*រាជ្យដោយធម៌ ។ ថ្ងៃមួយ ព្រះរាជានោះតាក់តែងបញ្ហាឈ្មោះ* **ធម្មយាគ** *(ការបូជាធម៌) ឡើង ទ្រង់ធ្វើសក្ការៈដល់ព្រាហ្មណ៍បុរោហិតឈ្មោះ សុចិរតៈ ដែលអង្គុយលើអាសនៈហើយ កាលសួរបញ្ហា ទើបត្រាស់ ៤ ព្រះគាថាថា*

រជ្ជញ្ច បដិបន្នាស្ម, អាធិបច្ចំ សុចីរត;
មហាត្តំ បត្តុមិច្ឆាមិ, វិជេតុំ បថវឹ ឥមំ។

*នែសុចីរតៈ យើងបាននូវរាជសម្បត្តិផង បាននូវភាពជាធំផង យើងប្រាថ្នា ដើម្បីដល់នូវភាពជាធំ ប្រាថ្នាដើម្បីត្រួតត្រានូវផែនដីនេះ ។*

ធម្មេន នោ អធម្មេន, អធម្មោ មេ ន រុច្ចតិ;
កិច្ចោវ ធម្មោ ចរិតោ, រញ្ញោ ហោតិ សុចីរត។

*(យើងប្រកប) ដោយធម៌ មិនប្រកបដោយអធម៌ទេ ព្រោះអធម៌មិនពេញចិត្តដល់យើងឡើយ ម្នាលសុចីរតៈ ធម៌ជាចរិតរបស់ព្រះរាជា ពួកជនត្រូវតែធ្វើ ។*

ឥធ ចេវានិន្ទិតា យេន, បេច្ច យេន អនិន្ទិតា;
យសំ ទេវមនុស្សេសុ, យេន បប្បោមុ ព្រាហ្មណ។

*នែព្រាហ្មណ៍ យើងដែលពួកជនមិននិន្ទា ក្នុងលោកនេះ ដោយអត្ថនិងធម៌ណាផង មិននិន្ទាក្នុងបរលោក ដោយអត្ថនិងធម៌ណាផង គប្បីដល់នូវឥស្សរិយយស ក្នុងទេវលោកនិងមនុស្សលោក ដោយអត្ថនិងធម៌ណាផង ។*

យោហំ អត្ថញ្ច ធម្មញ្ច, កត្តុមិច្ឆាមិ ព្រាហ្មណ;
តំ ត្វំ អត្ថញ្ច ធម្មញ្ច, ព្រាហ្មណក្ខាហិ បុច្ឆិតោ។

*នែព្រាហ្មណ៍ យើងប្រាថ្នាដើម្បីធ្វើនូវអត្ថនិងធម៌នោះៗ នែព្រាហ្មណ៍ អ្នកដែលយើងសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌នោះ ។*

*ពាក្យថា* **យើងបាននូវរាជសម្បត្តិ** *សេចក្តីថា បពិត្រអាចារ្យ យើងបានរាជសម្បត្តិក្នុងឥន្ទបត្តនគរដែលមានបរិមណ្ឌល ៧ យោជន៍ និងបានទទួលភាពជាធំក្នុងកុរុរដ្ឋដែលមានបរិមណ្ឌល ៣០០ យោជន៍ ។*

*បញ្ហានេះជ្រាលជ្រៅ ជាពុទ្ធវិស័យ គប្បីសួរបញ្ហានោះនឹងព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះ កាលព្រះសព្វញ្ញុពុទ្ធមិនមាន គួរសួរនឹងព្រះពោធិសត្វ ដែលជាអ្នកស្វែងរកនូវសព្វញ្ញុតញ្ញាណ ។ ចំណែកព្រាហ្មណ៍សុចិរតៈ មិនអាចនឹងឆ្លើយបញ្ហា ព្រោះភាពមិនមែនជាព្រះពោធិសត្វរបស់ខ្លួន កាលមិនអាច ក៏មិនធ្វើភាពជាបណ្ឌិត កាលនឹងប្រាប់នូវអសមត្ថភាពរបស់ខ្លួន ទើបពោលគាថាថា*

**ជាតញ្ញត្រ វិធុរា រាជ, ឯតទក្ខាតុមរហាតិ;**
**យំ ត្វំ អត្ថញ្ច ធម្មញ្ច, កត្តុមិច្ឆសិ ខត្តិយ។**

***បពិត្រព្រះខត្តិយរាជ ព្រះអង្គប្រាថ្នាដើម្បីធ្វើនូវអត្ថនិងធម៌ណា តែវៀរចាកវិធុរព្រាហ្មណ៍ហើយ បុគ្គលដទៃ មិនគួរនឹងប្រាប់នូវអត្ថនិងធម៌នោះបានទេ ។***

*គាថានោះមានសេចក្តីថា បពិត្រមហារាជ បញ្ហានោះមិនមែនជាវិស័យ របស់មនុស្សដែលដូចជាខ្ញុំ ។ ចំណែកខ្ញុំមិនឃើញខាងដើម និងទីបំផុតរបស់បញ្ហានោះ ខ្ញុំហាក់ដូចជាចូលដល់ការងងឹត ។ មានព្រាហ្មណ៍ឈ្មោះ វិធុរៈ ជាបុរោហិតរបស់ព្រះរាជាពារាណសី វិធុរៈនោះនឹងប្រាប់បញ្ហានោះ វៀរលែងតែគេចេញហើយ បុគ្គលដទៃណាមួយមិនអាចនឹងសម្តែងនូវអត្ថ និងធម៌ដែលព្រះអង្គប្រាថ្នានឹងធ្វើបានឡើយ ។*

ព្រះរាជាស្ដាប់ពាក្យរបស់សុចិរតៈនោះហើយ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើយ៉ាងនោះ លោកចូរទៅកាន់សម្នាក់របស់វិធុរៈនោះឲ្យឆាប់ ដូច្នេះហើយ ទ្រង់ឲ្យបណ្ណាការ ជាអ្នកប្រាថ្នានឹងបញ្ជូនសុចិរតៈនោះ ទើបត្រាស់ព្រះគាថាថា

**ឯហិ ខោ បហិតោ គច្ឆ, វិធុរស្ស ឧបន្តិកំ;**
**និក្ខញ្ចិមំ សុវណ្ណស្ស, ហរំ គច្ឆ សុចីរត;**
**អភិហារំ ឥមំ ទជ្ជា, អត្ថធម្មានុសិដ្ឋិយ។**

***នៃសុចីរតៈ អ្នកចូរមកនេះ អ្នកឯងត្រូវយើងប្រើឲ្យទៅ អ្នកចូរទៅកាន់សំណាក់នៃវិធុរ-ព្រាហ្មណ៍ ចូរនាំយកនូវឆ្ពោរនៃមាសនេះទៅចុះ អ្នកចូរឲ្យនូវឆ្ពោរនៃមាសនេះ ជាគ្រឿងបូជាដល់ការប្រៀនប្រដៅ នូវអត្ថនិងធម៌ ។***

ពាក្យថា និក្ខំ សេចក្ដីថា ៥ សុវណ្ណៈ ជា ១ និក្ខៈ ។ តែក្នុងអត្ថនេះ ព្រះរាជាប្រទានមានឆ្ពោរមួយពាន់ ទើបត្រាស់យ៉ាងនេះ ។ ពាក្យថា **ឥមំ ទជ្ជា** សេចក្ដីថា កាលវិធុរព្រាហ្មណ៍នោះពោលធម្មយាគបញ្ហានេះហើយ លោកគប្បីធ្វើការបូជាមាសឆ្ពោរមួយពាន់នេះដល់វិធុរៈនោះ ដើម្បីទទួលពាក្យអធិប្បាយអត្ថនិងធម៌ ។

ព្រះរាជាធនញ្ជយកោរព្យបានត្រាស់យ៉ាងនេះហើយ ទើបត្រាស់ឲ្យយកមាសដែលមានតម្លៃមួយសែនមកផែជាផែន ដើម្បីប្រយោជន៍ដល់ការចារឹកពាក្យវិសជ្ជនាបញ្ហា ឲ្យរៀបចំយានសម្រាប់ធ្វើដំណើរ ចាត់ពលកាយសម្រាប់ជាបរិវារ ប្រទានបណ្ណាការ និងបញ្ជូនសុចិរតៈឲ្យទៅ ក្នុងពេលនោះឯង ។ ចំណែកសុចិរតព្រាហ្មណ៍នោះ ចេញអំពីឥន្ទបត្តនគរ មិនបានទៅកាន់នគរពារាណសីដោយត្រង់ទេ បណ្ឌិតទាំងឡាយនៅក្នុងទីណាៗ ក៏ចូលទៅកាន់ទីនោះៗ ទាំងអស់ មិនបានទទួលការដោះស្រាយបញ្ហា សូម្បីទាំងសកលជម្ពូទ្វីប ទើប

ទៅដល់នគរពារាណសីជាលំដាប់ ហើយកាន់យកនិវាសក្នុងកន្ទែងមួយ ។ ក្នុងវេលាដែលបរិភោគអាហារព្រឹករួច សុចិរតព្រាហ្មណ៍ក៏ទៅកាន់និវេសន៍របស់វិធុរបណ្ឌិត ជាមួយនឹងជនជាបរិវារពីរបីនាក់ (កាលទៅដល់ហើយ) ក៏ប្រាប់រឿងរ៉ាវដែលគាត់មក ត្រូវវិធុរៈហៅឲ្យចូលទៅ គាត់ឃើញវិធុរៈកំពុងបរិភោគ ក្នុងផ្ទះខ្លួន ។

ព្រះសាស្ដាកាលធ្វើសេចក្ដីនោះ ឲ្យជាក់ច្បាស់ ទើបត្រាស់ព្រះគាថាទី ៧ ថា

ស្វាធិប្បាគា ភារទ្វាជោ, វិធុរស្ស ឧបន្តិកំ,
តមទ្ទស មហាព្រហ្មា, អសមាធំ សកេ ឃរេ។

សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់នៃវិធុរព្រាហ្មណ៍ សុចិរតៈ ជាមហាព្រាហ្មណ៍ក៏បានឃើញវិធុរព្រាហ្មណ៍នោះ កំពុងតែបរិភោគក្នុងផ្ទះរបស់ខ្លួន ។

សុចិតព្រាហ្មណ៍នោះ កាលនៅក្មេងជាសម្លាញ់នឹងវិធុរព្រាហ្មណ៍ បានរៀនសិល្បសាស្ត្រ ក្នុងត្រកូលអាចារ្យតែមួយ ព្រោះហេតុនោះ គាត់ទើបបរិភោគរួមជាមួយនឹងវិធុរព្រាហ្មណ៍នោះតែម្ដង ក្នុងកាលបរិភោគរួច ទើបអង្គុយជាសុខ ត្រូវវិធុរៈសួរថា នែសម្លាញ់ អ្នកមកដើម្បីប្រយោជន៍អ្វី កាលនឹងប្រាប់ហេតុនៃការមក ទើបពោលគាថាទី ៨ ថា

រញ្ញោហំ បហិតោ ទូតោ, កោរព្យស្ស យសស្សិនោ;
‘អត្ថំ ធម្មញ្ច បុច្ឆេសិ, ឥច្ចព្រវិ យុធិដ្ឋិលោ;
តំ ត្វំ អត្ថញ្ច ធម្មញ្ច, វិធុរក្ខាហិ បុច្ឆិតោ។

*ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទធនញ្ជយកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់មានព្រះឱង្ការថា អ្នកចូរសួរនូវអត្ថនិងធម៌ បពិត្រវិធុរៈ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌នោះ ។*

*ពាក្យថា* ***អ្នកចូរសួរ*** *សេចក្តីថា ព្រះបាទធនញ្ជយយុធិដ្ឋិលគោត្រនោះសួរបញ្ហាឈ្មោះធម្មយាគនឹងខ្ញុំ ខ្ញុំកាលមិនអាចនឹងឆ្លើយ ហើយដឹងថា អ្នកអាចឆ្លើយបាន ទើបប្រាប់ដល់ព្រះរាជានោះ ព្រះរាជានោះប្រទានបណ្ណាការ និងបញ្ជូនខ្ញុំមកកាន់សម្នាក់អ្នក ដើម្បីប្រយោជន៍ដល់ការសួរបញ្ហា ទ្រង់បានត្រាស់ថា អ្នកគប្បីទៅកាន់សម្នាក់វិធុរៈហើយសួរអត្ថផង បាលីធម្មផងនៃបញ្ហានេះ ។ ឥឡូវនេះ យើងសួរអ្នកហើយ អ្នកគប្បីប្រាប់បញ្ហានោះ ។*

*ក្នុងពេលនោះ វិធុរព្រាហ្មណ៍នោះគិតថា យើងនឹងកាន់ចិត្តរបស់មហាជន ដូច្នេះទើបពិចារណាការវិនិច្ឆ័យ ហាក់ដូចជាបិទទឹកទន្លេគង្គា ។ ឱកាសក្នុងវិសជ្ជនាបញ្ហារបស់វិធុរ-ព្រាហ្មណ៍នោះ មិនមាន ។ វិធុរព្រាហ្មណ៍នោះកាលប្រាប់សេចក្តីនោះ ទើបពោលគាថាទី ៩ ថា*

**គង្គំ មេ បិទហិស្សន្តិ, ន តំ សក្កោមិ ព្រាហ្មណ;**
**អបិធេតុំ មហាសិន្ធុំ, តំ កាជំ សោ ករិស្សតិ;**
**ន តេ សក្កោមិ អក្ខាតុំ, អត្ថំ ធម្មញ្ច បុច្ឆិតោ។**

*ម្នាលព្រាហ្មណ៍ ខ្ញុំ (គិតថា) អញនឹងបិទនូវទន្លេគង្គា តែមិនអាចបិទនូវទន្លេដ៏ធំនោះបាន ព្រោះហេតុនោះ ឱកាសនោះ នឹងមានដូចម្តេចកើត ខ្ញុំដែលអ្នកសួរហើយមិនអាចដើម្បីប្រាប់នូវអត្ថនិងធម៌បានទេ ។*

*គាថានោះមានសេចក្ដីថា ម្នាលព្រាហ្មណ៍ ខ្ញុំកើតសេចក្ដីខ្វល់ខ្វាយចិត្តថា យើងនឹងបិទទន្លេគង្គា ពោលគឺចិត្តគតិផ្សេងៗរបស់មហាជន ដូច្នេះកាលខ្ញុំមិនអាចនឹងបិទមហាទន្លេនោះ ព្រោះហេតុនោះ ឱកាសនោះនឹងមានដូចម្ដេចកើត ខ្ញុំគប្បីវិសជ្ជនាបញ្ហាដល់អ្នក បានយ៉ាងណា ។ កាលមិនបានការគិតតែមួយ និងឱកាស ដូច្នេះ ខ្ញុំទើបមិនអាចប្រាប់អត្ថនិងធម៌ដែលអ្នកសួរ ។*

*វិធុរព្រាហ្មណ៍ពោលយ៉ាងនេះហើយ ក៏ពោលទៀតថា បុត្រយើងជាបណ្ឌិតជាអ្នកប្រាជ្ញាជាងខ្ញុំ បុត្រនោះនឹងព្យាករដល់អ្នក អ្នកចូរទៅកាន់សម្នាក់បុត្រចុះ ដូច្នេះហើយគាត់ទើបពោលគាថាទី ១០ ថា*

**ភទ្រការោ ច មេ បុត្តោ, ឱរសោ មម អត្រជោ;**
**តំ ត្វំ អត្ថញ្ច ធម្មញ្ច, គន្ត្វា បុច្ឆស្សុ ព្រាហ្មណ។**

***តែខ្ញុំមានកូនប្រុសមួយឈ្មោះភទ្រការ ជាឱរស ជាកូនបង្កើតរបស់ខ្ញុំ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរអត្ថនិងធម៌ ចំពោះភទ្រការនោះចុះ ។***

*សុចិរតព្រាហ្មណ៍ស្ដាប់ពាក្យនោះហើយ ក៏ចេញពីផ្ទះរបស់វិធុរៈ ទៅកាន់និវេសន៍របស់ភទ្រការដែលបានបរិភោគអាហារព្រឹករួចអង្គុយកណ្ដាលបរិស័ទរបស់ខ្លួន ។*

*ព្រះសាស្ដាកាលប្រកាសសេចក្ដីនោះ ទើបត្រាស់ព្រះគាថាទី ១១ ថា*

**សោធិប្បាគា ភារទ្វាជោ, ភទ្រការស្សុបត្តិកំ;**
**តមទ្ទស មហាព្រហ្មា, និសិន្នំ សម្ហិ វេស្មនិ។**

*សុចិរតព្រាហ្មណ៍ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់ភទ្រការកុមារ សុចិរតៈជាមហាព្រាហ្មណ៍បានឃើញភទ្រកុមារនោះ កំពុងអង្គុយនៅក្នុងផ្ទះរបស់ខ្លួន ។*

សុចិរតៈនោះទៅក្នុងទីនោះ ជាអ្នកដែលភទ្រការមាណព ធ្វើការទទួលដោយគ្រឿងសក្ការៈហើយសួរហេតុនៃការមក ទើបពោលគាថាទី ១២ ថា

រញ្ញោហំ បហិតោ ទូតោ, កោរព្យស្ស យសស្សិនោ;
'អត្ថំ ធម្មញ្ច បុច្ឆេសិ, ឥច្ចព្រវិ យុធិដ្ឋិលោ;
តំ ត្វំ អត្ថញ្ច ធម្មញ្ច, ភទ្រការ បព្រូហិ មេ។

*ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈ ដ៏មានយស ទ្រង់ប្រើមក ព្រះបាទធនញ្ជយកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ ម្នាលភទ្រការកុមារ ព្រោះហេតុនោះ អ្នកចូរប្រាប់នូវអត្ថនិងធម៌នោះ ដល់ខ្ញុំ ។*

លំដាប់នោះ ភទ្រការពោលថា បពិត្រលោកដ៏ចម្រើន ក្នុងថ្ងៃទាំងឡាយនេះ ខ្ញុំរវល់តែតម្កល់ខ្ជាប់ក្នុងបរទារិកកម្ម (អំពើដែលបុរសប្រព្រឹត្តខុសចំពោះប្រពន្ធរបស់អ្នកដទៃ គឺអំពើលួចប្រពន្ធគេ)ចិត្តរបស់ខ្ញុំមួហ្មង ដោយហេតុនោះ ខ្ញុំទើបមិនអាចនឹងវិសជ្ជនាដល់លោក តែប្អូនរបស់ខ្ញុំឈ្មោះ សញ្ជយកុមារ គេមានប្រាជ្ញាក្រៃលែងជាងខ្ញុំ លោកចូរសួរបញ្ហានោះនឹងគេចុះ គេនឹងវិសជ្ជនាបញ្ហាដល់លោក ដូច្នេះហើយ កាលនឹងបញ្ជូនព្រាហ្មណ៍នោះទៅកាន់សម្នាក់របស់សញ្ជយកុមារ ទើបពោលគាថា ២ ថា

មំសកាជំ អវហាយ, គោធំ អនុបតាមហំ;
ន តេ សក្កោមិ អក្ខាតុំ, អត្ថំ ធម្មញ្ច បុច្ឆិតោ។

ខ្ញុំទើបទម្លាក់ចោលនូវអម្រែកសាច់ហើយ ដេញនូវទន្សង ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់ នូវអត្ថនិងធម៌បានទេ ។

សញ្ជយោ នាម មេ ភាតា, កនិដ្ឋោ មេ សុចីរត;
តំ ត្វំ អត្ថញ្ច ធម្មញ្ច, គន្ត្វា បុច្ឆស្សុ ព្រាហ្មណា។

បពិត្រសុចិរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ឈ្មោះសញ្ជ័យ បពិត្រសុចិរតព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរ នូវអត្ថនិងធម៌ ចំពោះសញ្ជ័យនោះចុះ ។

ពាក្យថា **អម្រែកសាច់** សេចក្ដីថា កាលបុរសកាន់យកអម្រែកសាច់ម្រឹគជាត់ ត្រាច់ទៅបានឃើញទន្សងតូច ក្នុងរវាងផ្លូវ ហើយលះចោលអម្រែកសាច់ ដេញតាមទន្សងនោះ យ៉ាងណា ខ្ញុំនោះបានលះបង់ករិយាដែលជាអ្នកមានវត្តល្អនៅក្នុងផ្ទះរបស់ខ្លួន ហើយមកជាប់នឹងស្ត្រីដែលមានគេរក្សា របស់បុគ្គលដទៃ ក៏យ៉ាងនោះដែរ ។

ក្នុងខណៈនោះ សុចិរតព្រាហ្មណ៍ក៏ទៅកាន់និវេសន៍របស់សញ្ជយកុមារ ជាអ្នកដែលសញ្ជយកុមារធ្វើសក្ការៈហើយសួរហេតុនៃការមក ទើបប្រាប់ ។

ព្រះសាស្ដាកាលប្រកាសសេចក្ដីនោះ ទើបត្រាស់ ២ ព្រះគាថា ថា

ស្វាជិប្បាគា ភារទ្វាជោ, សញ្ជយស្ស ឧបន្តិកំ;
តមទ្ទស មហាព្រហ្មា, និសិន្នំ សម្ហិ វេស្មនិ។

សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះបានទៅកាន់សំណាក់សញ្ជយកុមារ សុចីរតៈជាមហាព្រាហ្មណ៍ បានឃើញនូវសញ្ជ័យកុមារនោះ អង្គុយក្នុងកណ្ដាលបរិស័ទរបស់ខ្លួន ។

រញ្ញោហំ បហិតោ ទូតោ,      កោរព្យស្ស យសស្សិនោ;
'អត្ថំ ធម្មញ្ច បុច្ឆេសិ,      ឥច្ចព្រវិ យុធិដ្ឋិលោ;
តំ ត្វំ អត្ថញ្ច ធម្មញ្ច,      សញ្ចយក្ខាហិ បុច្ឆិតោ។

*(សុចិរតព្រាហ្មណ៍ពោលថា) ខ្ញុំជាទូត របស់ព្រះបាទធនញ្ជយកោរព្យៈ ដ៏មានយស ព្រះរាជាទ្រង់ប្រើខ្ញុំមក ព្រះបាទធនញ្ជយកោរព្យៈ ជាយុធិដ្ឋិលគោត្រ មានព្រះឱង្ការថា អ្នកចូរសួរនូវអត្ថនិងធម៌ ម្នាលសញ្ជយកុមារ ព្រោះហេតុនោះ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌ ។*

*ក្នុងពេលនោះ សញ្ជយកុមារកំពុងតែសេពនឹងប្រពន្ធរបស់អ្នកដទៃ ។ លំដាប់នោះ គេទើបប្រាប់សុចិរតព្រាហ្មណ៍ថា បពិត្រលោកដ៏ចម្រើន ខ្ញុំកំពុងសេពនឹងប្រពន្ធរបស់អ្នកដទៃ កាលទៅសេពនឹងប្រពន្ធគេនោះ ខ្ញុំត្រូវឆ្លងទន្លេគង្គាទៅកាន់ត្រើយខាងនាយ ម្រឹត្យូវគឺសេចក្តីស្លាប់រមែងទំពាស៊ីខ្ញុំដែលកំពុងឆ្លងស្ទឹងទាំងព្រឹកទាំងល្ងាច ដោយហេតុនោះ ចិត្តរបស់ខ្ញុំទើបមួហ្មង ខ្ញុំមិនអាចនឹងប្រាប់ដល់លោកបានទេ តែប្អូនរបស់ខ្ញុំមានឈ្មោះថា* ***សម្ភវកុមារ*** *ជាអ្នកមានអាយុ ៧ ឆ្នាំ ជាអ្នកមានបញ្ញាក្រៃលែងជាងខ្ញុំដោយរយនៃគុណ ដោយពាន់នៃគុណ ដោយសែននៃគុណ គេនោះនឹងប្រាប់ដល់លោក លោកចូរទៅសួរបញ្ហានោះនឹងគេចុះ ។*

*ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថា ២ ថា*

សទា មំ គិលតេ មច្ចុ,      សាយំ បាតោ សុចីរត;
ន តេ សក្កោមិ អក្ខាតុំ,      អត្ថំ ធម្មញ្ច បុច្ឆិតោ។

*(សញ្ជយកុមារពោលថា) បពិត្រសុចិរតព្រាហ្មណ៍ មច្ចុតែងលេបខ្ញុំរាល់ព្រឹកល្ងាចសព្វៗ កាល ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់នូវអត្ថនិងធម៌ ដល់អ្នកបានទេ ។*

សម្ភវោ ឯាម មេ ភាតា, 　　កនិដ្ឋោ មេ សុចីរត,
តំ ត្វំ អត្ថញ្ច ធម្មញ្ច, 　　គន្ត្វា បុច្ឆស្សុ ព្រាហ្មណា។

*បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ ឈ្មោះសម្ភវៈ បពិត្រព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរនូវអត្ថនិងធម៌ ចំពោះសម្ភវៈនោះចុះ ។*

*សុចិរតៈស្តាប់ពាក្យនោះហើយ គិតថា បញ្ហានេះពិតជានឹងអស្ចារ្យក្នុងលោកមែន អ្នកមានសមត្ថភាពអាចនឹងវិសជ្ជនាបញ្ហានេះ រមែងមិនមាន ដូច្នេះទើបពោល ២ គាថា ថា*

អព្ភុតោ វត ភោ ធម្មោ, 　　ឯាយំ អស្មាក រុច្ចតិ;
តយោ ជនា បិតាបុត្តា, 　　តេ សុ បញ្ញាយ ជោ វិទូ។

*ម្នាលអ្នកដ៏ចម្រើន បញ្ហាធម៌ ដ៏អស្ចារ្យម្ល៉េះ សម្ភវកុមារនេះ យើងមិនពេញចិត្តទេ ព្រោះជន ៣ នាក់ ឪពុក និងកូនទាំងនោះ មិនដឹងច្បាស់ដោយប្រាជ្ញាទៅហើយ ។*

ឧ តំ សក្កោថ អក្ខាតុំ, 　　អត្ថំ ធម្មញ្ច បុច្ឆិតា;
កោជំ ឆុ ឧហរោ ជញ្ញា, 　　អត្ថំ ធម្មញ្ច បុច្ឆិតោ។

*អ្នកទាំងឡាយដែលខ្ញុំសួរហើយ មិនអាចប្រាប់នូវអត្ថនិងធម៌បាន ចំណង់បើកូនក្មេងដែលខ្ញុំសួរអត្ថ និងធម៌ហើយ គប្បីដឹងដូចម្តេចកើត ។*

*បទថា* ឯាយំ *សេចក្តីថា បញ្ហាធម៌នេះ អស្ចារ្យណាស់ អ្នកដែលអាចនឹងឆ្លើយ មិនមានព្រោះហេតុនោះ អ្នកពោលថា កុមារនេះនឹងឆ្លើយ មិនពេញចិត្តដល់ខ្ញុំទេ ។*

*សញ្ជយកុមារស្តាប់ពាក្យនោះហើយ ទើបប្រាប់ថា បពិត្រលោកដ៏ចម្រើន លោកកុំសម្គាល់ថា សម្ភវកុមារនៅក្មេង បើលោកត្រូវការអ្នកវិសជ្ជនាបញ្ហា លោកចូរទៅសួរនឹងគេចុះ កាលប្រកាសគុណរបស់សម្ភវកុមារដែលឧបមាដូចអ្នកបំភ្លឺអត្ថ ទើបពោល ១២ គាថាថា*

មា ឆំ ឧបហាសេតិ ឧញ្ញាសិ, អបុច្ឆិត្វាន សម្ភវំ;
បុច្ឆិត្វា សម្ភវំ ជញ្ញា, អត្ថំ ជម្មព្វ ព្រាហ្មណ។

*បពិត្រសុចីរតព្រាហ្មណ៍ លោកកុំសម្គាល់សម្ភវកុមារនោះថា នៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។*

យថាបិ ចន្ទោ វិមលោ, គច្ឆំ អាកាសធាតុយា;
សព្វេ តារាគណេ លោកេ, អាភាយ អតិរោចតិ។

*ព្រះចន្ទ្រប្រាសចាកមន្ទិល កាលដើរទៅតាមអាកាសធាតុ រុងរឿងកន្លងនូវពួកផ្កាយទាំងអស់ក្នុងលោក ដោយពន្លឺយ៉ាងណាមិញ ។*

ឯវម្បិ ទហរូបេតោ, បញ្ញាយោគេន សម្ភវោ;
មា ឆំ ឧបហាសេតិ ឧញ្ញាសិ, អបុច្ឆិត្វាន សម្ភវំ;
បុច្ឆិត្វា សម្ភវំ ជញ្ញា, អត្ថំ ជម្មព្វ ព្រាហ្មណ។

*បពិត្រសុចីរតព្រាហ្មណ៍ សម្ភវកុមារ ពិតជានៅក្មេងមែន (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ លោកកុំសំគាល់នូវសម្ភវ-កុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។*

យថាបិ រម្មកោ មាសោ, គិម្ហានំ ហោតិ ព្រាហ្មណ;
អតេវញ្ញេហិ មាសេហិ, ទុមបុប្ផេហិ សោភតិ។

បពិត្រព្រាហ្មណ៍ បណ្តាខែខាងគិម្ហរដូវទាំងឡាយ ខែចែត្ររុងរឿង ដោយផ្កាឈើទាំងឡាយ ជាងខែទាំងឡាយដទៃឯទៀត យ៉ាងណាមិញ ។

ឯវម្បិ ឧបាយុបេតោ, បញ្ញាយោគេន សម្ភវោ;
មា នំ ទហរោតិ ឧញ្ញាសិ, អបុច្ឆិត្វាន សម្ភវំ;
បុច្ឆិត្វា សម្ភវំ ជញ្ញា, អត្ថំ ធម្មញ្ច ព្រាហ្មណ។

សម្ភវកុមារ ពិតមែនតែនៅក្មេង (តែរុងរឿងកន្លង នូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញា និងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់សម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។

យថាបិ ហិមវា ព្រហ្មេ, បព្វតោ គន្ធមាទនោ;
នានារុក្ខេហិ សញ្ឆន្នោ, មហាភូតគណាលយោ;
ឱសធេហិ ច ទិព្វេហិ, ទិសា ភាតិ បវាតិ ច។

បពិត្រព្រាហ្មណ៍ ភ្នំគន្ធមាទនៈមានទឹកសន្សើម ជាលំនៅនៃពួកទេវតាដេរដាស ដោយដើមឈើផ្សេងៗទាំងឡាយផង ដោយឱសថជាទិព្វទាំងឡាយផង រមែងញុំាងទិសទាំងឡាយឲ្យភ្លឺច្បាស់ផង ផ្សាយទៅកាន់ទិសទាំងឡាយ (ដោយក្លិនក្រអូប) ផង យ៉ាងណា មិញ ។

ឯវម្បិ ឧបាយុបេតោ, បញ្ញាយោគេន សម្ភវោ;
មា នំ ទហរោតិ ឧញ្ញាសិ, អបុច្ឆិត្វាន សម្ភវំ;
បុច្ឆិត្វា សម្ភវំ ជញ្ញា, អត្ថំ ធម្មញ្ច ព្រាហ្មណ។

សម្ភវកុមារ ពិតមែនតែនៅក្មេង (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញា និងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់សម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។

យថាបិ ទារកោ ព្រហ្មេ, អច្ចិមាលី យសស្សិមា;
ជលមានោ វនេ គច្ឆេ, អនលោ កណ្ហវត្តនី។

បពិត្រព្រាហ្មណ៍ ភ្លើងប្រក្រតី ប្រកបដោយអណ្តាត មានអំណាច កាលឆេះនូវគុម្ពឈើក្នុងព្រៃ មិនចេះឆ្អែត រមែងញ៉ាំងពណ៌ខ្មៅឲ្យប្រព្រឹត្តទៅ ។

យតាសនោ ធូមកេតុ, ឧត្តមាហោវន្ទហោ;
និសីថេ បព្វតគ្គស្មឹ, បហូតេជោ វិរោចតិ។

ជាសការៈឆេះនូវខ្លាញ់ មានផ្សែងជាទង់ ឆេះនូវដងព្រៃស្ងួក មានរបស់សម្រាប់ឆេះដ៏ច្រើន រមែងរុងរឿងលើកំពូលភ្នំ ក្នុងវេលាយប់យ៉ាងណាមិញ ។

ឯវម្បិ ទហរូបេតោ, បញ្ញាយោគេន សម្ភវោ;
មា នំ ទហរោតិ ឧញ្ញាសិ, អបុច្ឆិត្វាន សម្ភវំ;
បុច្ឆិត្វា សម្ភវំ ជញ្ញា, អត្ថំ ធម្មញ្ច ព្រាហ្មណ។

សម្ភវកុមារ ពិតមែនតែនៅក្មេង (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញា និងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។

ជវេន ភទ្រំ ជានន្តិ, ពលិពទ្ទញ្ច វាហិយេ;
ទោហេន ធេនុំ ជានន្តិ, ភាសមានញ្ច បណ្ឌិតំ។

គេស្គាល់សេះល្អ ដោយល្បឿនផង ស្គាល់គោចម្រើនក្នុងការផ្ទុកផង ស្គាល់មេគោដោយរឹតនូវទឹកដោះផង ស្គាល់អ្នកប្រាជ្ញកាលនិយាយផង យ៉ាងណាមិញ ។

ឯវម្បិ ទហរូបេតោ, បញ្ញាយោគេន សម្ភវោ;

**មា នំ ទហរោតិ ឧញ្ញាសិ, អបុច្ឆិត្វាន សម្ភវំ;**
**បុច្ឆិត្វា សម្ភវំ ជញ្ញា, អត្ថំ ធម្មញ្ច ព្រាហ្មណា។**

*សម្ភវកុមារ ពិតមែនតែនៅក្មេង (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញា និងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់សម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។*

*បទថា* **ឯវម្បិ ទហរូបេតោ** *សេចក្ដីថា សម្ភវកុមារសូម្បីនៅក្មេង តែកន្លងនូវបណ្ឌិតដ៏សេសមិនមានសល់ទូទាំងសកលជម្ពូទ្វីប ដោយបញ្ញា ។*

*កាលសញ្ជយកុមារសរសើរសម្ភវកុមារយ៉ាងនេះហើយ សុចិរតៈគិតថា យើងសួរបញ្ហាហើយនឹងដឹង ហើយសួរសញ្ជយកុមារថា ម្នាលកុមារ ចុះប្អូនរបស់លោកនៅឯណា ។ លំដាប់នោះ សញ្ជយកុមារបើកសីហបញ្ជរ លាតដៃចង្អុល ពោលប្រាប់ថា កុមារណាមានសម្បុរដូចមាស កំពុងលេងជាមួយនឹងកុមារទាំងឡាយ ក្នុងចន្លោះផ្លូវ ក្បែរទ្វារប្រាសាទ នេះឯងជាប្អូនរបស់ខ្ញុំ លោកចូរទៅជិតហើយសួរគេចុះ គេនឹងឆ្លើយបញ្ហាដល់លោក ដោយពុទ្ធលីឡា ។ សុចិរតៈស្ដាប់ពាក្យរបស់សញ្ជយកុមារហើយ ក៏ចុះចាកប្រាសាទ ទៅកាន់សម្នាក់សម្ភវកុមារ ។ មានពាក្យសួរថា គាត់ទៅក្នុងពេលណា ? ឆ្លើយថា ទៅក្នុងពេលដែលសម្ភវកុមារដោះសំពត់ស្លៀក ហើយដាក់នៅនឹងក ឈរយកដៃទាំងពីរចាប់ដីលេង ។*

*ព្រះសាស្ដាកាលធ្វើសេចក្ដីនោះឲ្យជាក់ច្បាស់ ទើបត្រាស់ព្រះគាថាថា*

**ស្វាធិប្បាគា ភារទ្វាជោ, សម្ភវស្ស ឧបន្តិកំ,**
**តមទ្ទស មហាព្រហ្មា, កីឡមានំ ពហីបុរេ។**

សុចីរតព្រាហ្មណ៍ ជាការទ្វាជគោត្រនោះបានទៅកាន់សំណាក់នៃសម្ភវកុមារ សុចីរតៈជាមហាព្រាហ្មណ៍ បានឃើញនូវសម្ភវកុមារនោះ កំពុងលេងខាងក្រៅទីលំនៅ ។

សូម្បីព្រះមហាសត្វឃើញព្រាហ្មណ៍មកឈរនៅខាងមុខហើយ សួរថា បពិត្រលោកដ៏ចម្រើន លោកមក ដោយប្រយោជន៍អ្វី ? កាលព្រាហ្មណ៍ពោលថា ម្នាលកុមារ ខ្ញុំកាលត្រាច់ទៅទូទាំងជម្ពូទ្វីប មិនបានអ្នកអាចនឹងប្រាប់បញ្ហាដែលខ្ញុំសួរហើយ ទើបខ្ញុំមកកាន់សម្នាក់អ្នក ដូច្នេះហើយ ព្រោះពោធិសត្វគិតថា បានឮថា បញ្ហាដែលមិនមានអ្នកវិនិច្ឆ័យ អស់ទូទាំងសកលជម្ពូទ្វីប ព្រាហ្មណ៍នេះនាំមកកាន់សម្នាក់យើង យើងជាមនុស្សធំដោយបញ្ញា យ៉ាងនេះហើយ លោកត្រឡប់បានហិរិនិងឱត្តប្បៈ បោះចោលដុំដីដែលកាន់នឹងដៃ កាន់យកសំពត់អំពីក មកស្លៀក ហើយឲ្យបវារណាព្រាហ្មណ៍ដោយសព្វញ្ញុបវារណាថា ម្នាលព្រាហ្មណ៍ លោកចូរសួរមកចុះ ខ្ញុំនឹងពោលដល់លោកដោយពុទ្ធលីឡា ។

លំដាប់នោះ ព្រាហ្មណ៍សួរបញ្ហាដោយគាថាថា

រញ្ញោហំ បហិតោ ទូតោ, កោរព្យស្ស យសស្សិនោ;
'អត្ថំ ធម្មញ្ច បុច្ឆេសិ, ឥច្ចព្រវិ យុធិដ្ឋិលោ;
តំ ត្វំ អត្ថញ្ច ធម្មញ្ច, សម្ភវក្ខាហិ បុច្ឆិតោ។

ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈជាយុធិដ្ឋិលគោត្រ ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ នៃសម្ភវកុមារ ព្រោះហេតុនោះ អ្នកឯងដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌ ។

សេចក្តីនៃគាថានោះថា សម្ភវបណ្ឌិតប្រាកដដូចព្រះចន្ទ្រពេញបូណ៌មី នៅកណ្តាលអាកាស ។

*លំដាប់នោះ សម្ភវកុមារពោលថា បើយ៉ាងនោះ លោកចូរស្តាប់ចុះ កាលនឹងវិសជ្ជនាធម្មយាគបញ្ហា ទើបពោលគាថាថា*

**តគ្ឃ តេ អហមក្ខិស្សំ, យថាបិ កុសលោ តថា;**
**រាជា ច ខោ តំ ជាជាតិ, យទិ កាហាតិ វា ន វា។**

***បើដូច្នោះ អ្នកឈ្លាសវៃ (និយាយ) យ៉ាងណា ខ្ញុំនឹងប្រាប់អ្នក យ៉ាងនោះ ព្រះរាជានឹងទ្រង់ជ្រាប នូវប្រស្នានោះ ទោះបីព្រះអង្គ ធ្វើតាមក្តី មិនធ្វើតាមក្តី ។***

*កាលសម្ភវកុមារឈរសម្តែងធម៌ ដោយសំឡេងដ៏ពីរោះ នៅត្រង់ចន្លោះផ្លូវនោះ សំឡេងក៏ផ្សាយទៅ គ្រប់សង្កត់ទូទាំងនគរពារាណសីទាំងអស់ ដែលមានប្រមាណ ១២ យោជន៍ ។ លំដាប់នោះ ព្រះរាជា និងឧបរាជជាដើម ក៏មកប្រជុំគ្នាទាំងអស់ ។ ព្រះមហាសត្វញ៉ាំងព្រះធម្មទេសនាឲ្យបិតនៅកណ្តាលមហាជន ។*

*កាលសម្ភវកុមារ ប្តេជ្ញាការឆ្លើយបញ្ហា ដោយគាថាទាំងឡាយនេះហើយ ឥឡូវនេះ កាលនឹងឆ្លើយធម្មយាគបញ្ហា ទើបពោលថា*

**អជ្ជ សុវេតិ សំសេយ្យ, រញ្ញោ បុដ្ឋោ សុចីរត;**
**មា កត្វា អវសី រាជា, អត្ថេ ជាតេ យុធិដ្ឋិលោ។**

***បពិត្រសុចីរតព្រាហ្មណ៍ បុគ្គលដែលព្រះរាជាសួរថា (យើងធ្វើកុសល) ក្នុងថ្ងៃនេះឬ គប្បីទូលថា ក្នុងថ្ងៃស្អែកវិញ កាលបើសេចក្តីត្រូវការកើតឡើងហើយ ព្រះបាទកោរព្យៈ ជា យុធិដ្ឋិលគោត្រ កុំធ្វើតាមពាក្យ (នោះ) ហើយនៅស្ងៀមឡើយ ។***

**អជ្ឈត្តញ្ញេវ សំសេយ្យ, រញ្ញោ បុដ្ឋោ សុចីរត;**

កុម្មគ្គំ ន និវេសេយ្យ, យថា មូឡ្ហោ អចេតសោ។

*បុគ្គលដែលព្រះរាជាសួរហើយ គប្បីក្រាបបង្គំទូលនូវខន្ធបញ្ចកៈ ជាខាងក្នុងតែម្យ៉ាង សូមព្រះរាជាកុំសេពនូវផ្លូវខុស ដូចបុគ្គលវង្វេងដោយឥតចេតនា ។*

អត្តានំ នាតិវត្តេយ្យ, អធម្មំ ន សមាចរេ;
អតិត្ថេ នប្បតារេយ្យ, អនត្ថេ ន យុតោ សិយា។

*ព្រះរាជាកុំប្រព្រឹត្តកន្លងនូវអត្តភាព កុំប្រព្រឹត្តនូវអធម៌ កុំចម្លងគេក្នុងទីមិនមែនជាកំពង់ កុំប្រកបក្នុងសេចក្ដីវិនាសឡើយ ។*

យោ ច ឯតានិ ឋានានិ, កត្តុំ ជានាតិ ខត្តិយោ;
សទា សោ វឌ្ឍតេ រាជា, សុក្កបក្ខេវ ចន្ទិមា។

*លុះតែក្សត្រិយ៍ណា ទ្រង់ជ្រាបហើយធ្វើនូវហេតុទាំងឡាយនេះ ព្រះរាជានោះទើបចម្រើនរាល់ពេល ដូចជាព្រះចន្ទ្រក្នុងសុក្កបក្ស ។*

ញាតីនញ្ច បិយោ ហោតិ, មិត្តេសុ ច វិរោចតិ;
កាយស្ស ភេទា សប្បញ្ញោ, សគ្គំ សោ ឧបបជ្ជតិ។

*ព្រះរាជានោះប្រកបដោយប្រាជ្ញា រមែងជាទីស្រឡាញ់នៃពួកញាតិផង រុងរឿងក្នុងពួកមិត្តផង លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងឋានសួគ៌ ។*

*លោកពោលអធិប្បាយថា បពិត្រសុចិរតៈ បើព្រះរាជារបស់លោក សួរអ្នកណាមួយថា ថ្ងៃនេះ យើងឲ្យទាន រក្សាសីល និងធ្វើឧបាសថកម្មឬ ? បើមានអាមាត្យណាមួយទូលថា បពិត្រមហារាជ ថ្ងៃនេះ ព្រះអង្គចូរសម្លាប់សត្វ ចូរសោយកាម ចូរផឹកសុរា ជាដំបូង ហើយចាំ*

ថ្ងៃស្អែក សូមទ្រង់ធ្វើកុសលចុះ ដូច្នេះ កាលព្រះរាជាយុធិដ្ឋិលគោត្ររបស់លោកធ្វើតាមពាក្យរបស់អាមាត្យដែលជាធំនោះ កាលអត្ថដែលមានសភាពបែបនោះកើតឡើងហើយ កុំញុំាងថ្ងៃនោះឲ្យកន្លងទៅដោយសេចក្តីប្រមាទ ហើយនៅស្ងៀមឡើយ ព្រះរាជាមិនត្រូវធ្វើតាមពាក្យរបស់អាមាត្យនោះទេ ត្រូវរក្សាកុសលចិត្តដែលកើតឡើងហើយមិនឲ្យសាបសូន្យ ត្រូវធ្វើកម្មដែលប្រកបដោយកុសលតែម្យ៉ាង លោកចូរទូលពាក្យនេះដល់ព្រះរាជារបស់លោក ។

ព្រះមហាសត្វសម្តែងកទ្ទេករត្តសូត្រដោយគាថានេះ យ៉ាងនេះថា

**អជ្ជេវ កិច្ចមាតប្បំ, កោ ជញ្ញា មរណំ សុវេ។**

បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន (មជ្ឈិមនិកាយ ឧបរិបណ្ណាសក វិភង្គវគ្គ) ។

និងសម្តែងអប្បាមាទោវាទថា

**អប្បមាទោ អមតបទំ, បមាទោ មច្ចុនោ បទំ។**

សេចក្តីមិនប្រមាទជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ (ខុទ្ទកនិកាយ ធម្មបទ អប្បមាទវគ្គ)។

បពិត្រសុចិរត: លោកដែលព្រះរាជាសួរថា សម្តវបណ្ឌិតដែលលោកសួរក្នុងធម្មយាគបញ្ហា គេនឹងឆ្លើយដូចម្តេច លោកគប្បីទូលអជ្ឈត្តធម៌តែម្យ៉ាងដល់ព្រះរាជារបស់លោក លោកគប្បីពោលថា អជ្ឈត្តធម៌ជាខន្ធកញ្ចក: ជារបស់មិនមាន និងមិនទៀង ។

ដោយពាក្យប៉ុណ្ណោះ ព្រះមហាសត្វសម្តែងអនិច្ចតាធម៌ ដោយគាថានេះថា

**សព្វេ សង្ខារា អនិច្ចាតិ, យទា បញ្ញាយ បស្សតិ។**

*កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀងដូច្នេះ* (ខុទ្ទក-និកាយ ធម្មបទ មគ្គវគ្គ)។

**អធិប្បា វត សង្ខារា, ឧប្បាទវយធម្មិនោ។**

*សង្ខារទាំងឡាយ មិនទៀងហ្ន៎ មានកិរិយាកើតឡើងនិងការសូន្យទៅ ជាធម្មតា* (ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ) ។

ម្នាលព្រាហ្មណ៍ អន្ធពាលបុថុជ្ជនល្ងង់ខ្លៅមិនមានការគិត តែងសេពផ្លូវខុស ពោលគឺ មិច្ឆាទិដ្ឋិ ៦២ យ៉ាងណា ព្រះរាជារបស់លោកមិនគប្បីសេពផ្លូវខុសនោះ ចូរសេពផ្លូវគឺកុសល-កម្មបទ ១០ ដែលជានិយ្យានិកៈប៉ុណ្ណោះ លោកគប្បីទូលព្រះរាជាយ៉ាងនេះ ។

ព្រះមហាសត្វឆ្លើយបញ្ហា ដល់ព្រាហ្មណ៍ ដោយពុទ្ធលីឡា ហាក់ដូចជាព្រះចន្ទ្ររះឡើងកណ្តាលអាកាស ។ មហាជនកាលបន្លឺសំឡេងឡើង បានទះដៃ ឲ្យសាធុការទាំងពាន់ និងលើកសំពត់ជាទង់ ផ្ទាត់ម្រាមដៃ ទាំងបោះគ្រឿងប្រដាប់ដៃជាដើម។ ទ្រព្យដែលមហាជនបោះទៅយ៉ាងនេះ មានប្រមាណមួយកោដិ ។ សូម្បីព្រះរាជាទ្រង់មានហឫទ័យត្រេកអរ បានប្រទានយសដ៏ធំដល់ព្រះពោធិសត្វ ។ ចំណែកសុចិរតព្រាហ្មណ៍ធ្វើការបូជាដោយមាសក្តោរមួយពាន់ហើយ ក៏សរសេរការវិសជ្ជនាបញ្ហា ដោយជាតិហិង្គុល លើផែនមាស រួចទៅកាន់ឥន្ទបត្តនគរ សម្តែងធម្មយាគបញ្ហាដល់ព្រះរាជារបស់ខ្លួន ។ ព្រះរាជាញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ទ្រង់បានកើតក្នុងសគ្គបុរី ។

ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន តថាគតក៏ជាអ្នកមានមហាបញ្ញាដែរ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា

**តទា ជនញ្ញាយរាជា អានន្ទោ អហោសិ** *ព្រះបាទជនញ្ញយរាជក្នុងកាលនោះបានមកជាអានន្ទ*

**សុចិរតោ អនុរុទ្ធោ** *សុចិរតព្រាហ្មណ៍បានមកជាអនុរុទ្ធ*

**វិធុរោ កស្សបោ** *វិធុរបណ្ឌិតបានមកជាកស្សបៈ*

**ភទ្រការោ មោគ្គល្លានោ** *ភទ្រការមាណពបានមកជាមោគ្គល្លាន*

**សញ្ជយមាណវោ សារិបុត្តោ** *សញ្ជយមាណពបានមកជាសារីបុត្រ*

**សម្ភវបណ្ឌិតោ បន អហមេវ អហោសិំ** *ចំណែកសម្ភវបណ្ឌិត គឺតថាគតនេះឯង ។*

*សម្ភវជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តឹសនិបាត បិដកលេខ ៦០ ទំព័រ ១៨០)*

*ថ្ងៃសៅរ៍ ៥ កើត ខែជេស្ឋ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ១៩ ខែ ឧសភា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*